- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និងកីឡា ស្រុក កំពង់ត្របែក ខេត្តព្រៃវែង លេខ ៩០-៩៥ ចុះថ្ងៃទី ១៤ -១០ - ១៩៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំ យុវជន និង កីឡា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ប្តូរ ឈ្មោះសាលាបឋមសិក្សាវត្តថ្កូវ នៅភូមិត្បែង ឃុំថ្កូវ ស្រុក កំពង់ត្របែក ខេត្តព្រៃវែង មកជា « សាលាបឋមសិក្សា **ស ខេង** វត្តថ្កូវ » ចាប់ពីឆ្នាំសិក្សា ១៩៩៥ - ១៩៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុក ជានិរាករណ៍ ។

ប្រការ ៣ : មន្ទីរក្រសួងអប់រំ យុវជន និង កីឡា នាយកដ្ឋានចាត់តាំង នាយកដ្ឋាន ផែនការ ហិរញ្ញកិច្ច នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក កំពង់ត្របែក សាលាបឋមសិក្សា **ស ខេង** វត្តថ្កូវមានភារៈ កិច្ចអនុវត្តប្រកាស នេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
**គា សាវាន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ១១៥ អយក.ប្រក**

**ស្តីពីការបើកវិទ្យាល័យ សិរីមង្គល ជាឧបសម្ព័ន្ធរបស់វិទ្យាល័យ**

**ព្រែកអញ្ចាញ ក្នុងស្រុកមុខកំពូល ខេត្តកណ្តាល**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រប. ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះ ទូទៅ ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពី ការបើកសាលា មធ្យមសិក្សាកំរិត១ - កំរិត២
- យោងសំណើរបស់ព្រះសង្ឃ និងសមាគមមាតាបិតាសិស្សអនុវិទ្យាល័យ សិរីមង្គល ដោយ មានការឯកភាពពីប្រធានមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្ត ខេត្តកណ្តាល
- តាមសំណើរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកណ្តាល បើកវិទ្យាល័យសិរីមង្គល ជា ឧបសម្ព័ន្ធរបស់វិទ្យាល័យព្រែកអញ្ចាញ ក្នុងស្រុកមុខកំពូល ខេត្តកណ្តាល ចាប់ពីឆ្នាំសិក្សា ១៩៩៥ - ១៩៩៦ តទៅ ។

**ប្រការ ២** : វិទ្យាល័យសិរីមង្គល ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់វិទ្យាល័យ ព្រែកអញ្ចាញ ។

**ប្រការ ៣** : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះទុកជានិរាករណ៍ ។

**ប្រការ ៤** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋាន បុគ្គលិក ប្រធាននាយកផែនការ ហិរញ្ញកិច្ច នៃក្រសួងអប់រំ

យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា និង នាយកវិទ្យាល័យ ព្រែកអញ្ចាញមាន ភារៈកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**តូល ឡោះ**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ១១៦ អយក.ប្រក**

**ស្តីពីការរៀបចំប្រព្រឹត្តិទៅនៃការប្រលងសញ្ញាបត្រ**

**មធ្យមសិក្សាកំរិត ២**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ២២៣៧ សជណ.អវ ចុះថ្ងៃទី ១៩-១១-១៩៩០ ស្តីពីការប្តូរឈ្មោះសាលារៀនចំណេះទូទៅ
- បានឃើញប្រកាសក្រសួងលេខ ២៣២៩ ចុះថ្ងៃទី ១៧.៥.១៩៨០ ស្តីពីការប្រលងសញ្ញាប័ត្រកំរិតសិក្សាទី ៣